ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយដំឡូងមី ២០១៨-២០២២

**រាជរដ្ឋាភិបាលកម្ពុជា**

# មាតិកា

សេចក្តីផ្តើម ........................................ 3
ទស្សនៈវិស័យទីផ្សារ ........................................ 5
ចក្ខុវិស័យ និងទិសដៅយុទ្ធសាស្ត្រ ........................................ 8
យុទ្ធសាស្ត្រដើម្បីសម្រេចបានគោលដៅនៃគោលនយោបាយទាំងនេះ ........................................ 11
វិធានការគោលនយោបាយ ........................................ 12
ហានិភ័យ និងការកាត់បន្ថយ ........................................ 18
ការរៀបចំអភិបាលកិច្ចវិស័យដំឡូងមី ........................................ 19
សេចក្តីសន្និដ្ឋាន ........................................ 20

# ឯកសារគោលនយោបាយ
# ការកសាងផលិតកម្មដំឡូងមីប្រកបដោយនិរន្តរភាព
# សម្រាប់ការនាំចេញផលិតផលកែច្នៃ ទៅកាន់ទីផ្សារ

--------------------

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចកំណើនសេដ្ឋកិច្ចដ៏រឹងមាំអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ដែលបានរួមចំណែកធ្វើឱ្យកម្ពុជាទទួលបានកិត្តិនាមជាសេដ្ឋកិច្ចខ្លាថ្មីនៅអាស៊ី[1]។ កំណើនថេរនេះ បានផ្តល់ជាលទ្ធផលនូវការកាត់ បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់ ហើយបានធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជនកម្ពុជាជាច្រើនលាននាក់។ ជោគជ័យនៃសេដ្ឋកិច្ចនេះ កើតចេញពីសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការរក្សាសន្តិភាព ស្ថិរភាព និងសមាហរណកម្មសង្គមដែលជាមូលដ្ឋានគ្រឹះនៃកំណែទម្រង់រដ្ឋបាលទាន់ពេលវេលា និងការអនុវត្តគោនយោបាយប្រកបដោយប្រសិទ្ធភាពក្នុងការទាក់ទាញការវិនិយោគ ក៏ដូចជាការធ្វើសមាហរណកម្មសេដ្ឋកិច្ចដោយរលូនទៅក្នុងសេដ្ឋកិច្ចពិភពលោក និងសេរីភាវូបនីយកម្មពាណិជ្ជកម្ម។ គោលនយោបាយទាំងនេះ បានជំរុញការអភិវឌ្ឍវិស័យផ្សេងៗទៀត ដូចជា វិស័យទេសចរណ៍ កាត់ដេរសម្លៀកបំពាក់ សំណង់ និងការនាំចេញអង្ករ។

ដើម្បីរក្សាកំណើនសេដ្ឋកិច្ច និងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក ព្រមទាំងប្រែក្លាយកម្ពុជា ពីប្រទេសដែលមានការអភិវឌ្ឍតិចតួច ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន ពីវិស័យនានាដែលមានលក្ខណៈជាប្រពៃណី។ ប្រការនេះ ត្រូវបានគេមើលឃើញថា ជាច្រកចេញឆ្ពោះទៅកាន់ខ្សែសង្វាក់តម្លៃថ្មីៗដែលមានលក្ខណៈសកម្ម និងមានសក្តានុពលបច្ចុប្បន្ន។ ការផ្លាស់ប្តូរពីផលិតកម្មកសិកម្មលក្ខណៈគ្រួសារ ទៅជាការអភិវឌ្ឍដែលមានមូលដ្ឋានកសិ-ឧស្សាហកម្ម គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពសំខាន់ៗដ៏ទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតការងារថ្មី និងកាន់តែប្រសើរឡើង និងការអភិវឌ្ឍជំនាញ។ ជាលទ្ធផលកិច្ចប្រឹងប្រែងនេះ បានបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកម្ពុជា និងការតភ្ជាប់ទំនាក់ទំនងអន្តរវិស័យ ក្នុងការពង្រីកវិសាលភាពសេដ្ឋកិច្ចរបស់ប្រទេស។

ក្នុងចំណោមអាទិភាពជាច្រើន រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់នូវសក្តានុពលរបស់ដំឡូងមី ជាដំណាំមួយប្រភេទសម្រាប់កសិករដែលមានធនធានតិចតួច និង/ឬ កសិករខ្នាតតូច ដើម្បីកែលម្អជីវភាពរស់នៅរបស់ពួកគេ និងជាប្រភពមួយនៃការអភិវឌ្ឍឧស្សាហកម្ម។ ការរំពឹងទុកដ៏ត្រចះត្រចង់នេះ មានលក្ខណៈស្របគ្នាជាមួយពិភពលោកដែលឲ្យតម្លៃទៅលើដំឡូងមី ថាជាដំណាំសតវត្សរ៍ទី២១ ឬជាស្បៀងអាហារសតវត្សរ៍ទី ២១ ។

---

[1] ADB (2016) *Here Comes Cambodia: Asia's New Tiger Economy*, 10 May 2016, https://www.adb.org/news/features/here-comes-cambodia-asia-s-new-tiger-economy.

ជាច្រើនទសវត្សរ៍មកនេះ រាជរដ្ឋាភិបាលកម្ពុជា បានរក្សាជំរុញការអភិវឌ្ឍដំណាំដំឡូងមី និងបានទទួលស្គាល់ថា៖

**ការរីកលូតលាស់ដ៏អស្ចារ្យនៃផលិតកម្មដំឡូងមី៖** ការរីកចម្រើនយ៉ាងឆាប់រហ័សនៃតំបន់ដាំដុះដំឡូងមីក្នុងទសវត្សរ៍ចុងក្រោយនេះ មានន័យថា វាជាដំណាំដំឡូងមីធំបំផុតទីពីរនៅក្នុងប្រទេស។ ដំឡូងមី ត្រូវបានគេប៉ាន់ប្រមាណថា នឹងរួមចំណែករវាង ៣% ទៅ ៤% នៃផលិតផលក្នុងស្រុកសរុប។ ជារៀងរាល់ឆ្នាំ ថវិកាស្មើរតែ ៣០០ លានដុល្លារអាមេរិក ត្រូវបានគេវិនិយោគ ដើម្បីដាំដុះដំឡូងមី លើផ្ទៃដីដាំដុះចំនួន ០,៥ លានហិកតា ខណៈដែលការនាំចេញភាគច្រើននៅក្នុងទម្រង់ជាផលិតផលមិនទាន់កែច្នៃ និងជាចំណិតដំឡូងមីក្រៀម មានតម្លៃប្រហែល ៧២៨ លានដុល្លារ[2]។ វិស័យនេះ បានស្រូបយកការចូលរួមរបស់អ្នកជនបទច្រើនជាង ៩០០០០ គ្រួសារ នៅក្នុងខេត្តចំនួន ១៣ ក្នុងការដាំដុះដំឡូងមី និងបានបង្កើតការងារតាមរដូវកាលជាច្រើនសម្រាប់កម្លាំងពលកម្មក្នុងស្រុក។ មានមជ្ឈមណ្ឌលប្រមូលទិញផលិតផលដំឡូងមីចំនួន ៥៥០ កន្លែង នៅក្នុងខេត្តធំ ៗ ចំនួនប្រាំ។ ខេត្តទាំងនេះ មានផ្លូវតភ្ជាប់ទៅកាន់កំពង់ផែជិតៗដោយផ្ទាល់សម្រាប់ការនាំចេញទៅកាន់ប្រទេសជិតខាង។ មានរោងចក្រកែច្នៃម្សៅមីចំនួន ៥ ក្នុងចំណោម ១០ រោងចក្រ ដែលកំពុងប្រតិបត្តិការ ខណៈដែលមានរោងចក្រកែច្នៃថ្មីមួយកំពុងដំណើរការរៀបចំ។ មានរោងចក្រចម្រាញ់អេតាណុលចេញពីផលិតផលដំឡូងមី ចំនួន ២ នៅជិតទីក្រុងភ្នំពេញ បានប្រតិបត្តិការអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

**ការងើបឡើងនៃផលិតកម្មដំឡូងមីនៅកម្ពុជា៖** ការកើនឡើងតម្រូវការនៃចំណិតដំឡូងមីស្ងួត សម្រាប់ការផលិតអេតាណុល និងម្សៅមីនៅក្នុងប្រទេសចិន បានបង្កើតប្រព័ន្ធពាណិជ្ជកម្មដ៏រស់រវើកមួយលើវិស័យនេះ រវាងអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍។ និយាយដោយសាមញ្ញ ប្រព័ន្ធនេះមើលឃើញថាប្រទេសចិន ជាប្រទេសមហាអំណាចមួយ ហើយប្រទេសថៃឡង់ដ៏ និងវៀតណាម គឺជាអ្នកផ្គត់ផ្គង់ដ៏សំខាន់ក្នុងតំបន់ ខណៈកម្ពុជាគឺជាអ្នកផលិត។ ប្រទេសទាំងពីរនេះ មិនអាចពង្រីកតំបន់ដាំដុះដំឡូងមីរបស់ខ្លួនបានទេ ដោយសារតែមានការប្រកួតប្រជែងជាមួយដំណាំផ្សេងៗ ទៀត (តម្លៃបន្ថែម និងមានតម្លៃខ្ពស់) និងគោលនយោបាយរដ្ឋាភិបាលរបស់ពួកគេអនុញ្ញាតឱ្យតែដីដែលមានជីជាតិតិច និងដីដែលគ្មានប្រព័ន្ធស្រោចស្រពសម្រាប់ការដាំដុះដំឡូងមី។ ធ្វើជាអ្នកផ្គត់ផ្គង់ដែលអាចជឿទុកចិត្តបានដល់ប្រទេសចិន និងពិភពលោក ប្រទេសថៃឡង់ដ៏ និងវៀតណាម បង្កើតបាននូវទីផ្សារដំឡូងមីសម្រាប់ប្រទេសកម្ពុជា និងប្រព័ន្ធគាំទ្រដោយប្រយោលជាប្រភពកសិ-ឧស្សាហកម្ម ដែលវត្ថុធាតុបម្រើឲ្យវិស័យកសិកម្មត្រូវបានគេលក់ ហើយការអនុវត្តផ្នែកកសិកម្មត្រូវបានគេចែករំលែកក្រៅផ្លូវការដល់កសិករ។ ជាលទ្ធផលដំណាំដំឡូងមីត្រូវបានលូតលាស់ភាគច្រើននៅតាមបណ្តោយព្រំដែន ហើយជាបន្តបន្ទាប់បានរីករាលដាលចូលទៅក្នុងតំបន់ដែលមានដីទំនេរ ដូចជា ដីដាំស្វាយចន្ទី និងចម្ការកៅស៊ូ និង/ឬ ដីដែលទើបនឹងកាប់ព្រៃហើយថ្មីៗ។

**រចនាសម្ព័ន្ធខ្សែសង្វាក់តម្លៃក្នុងតំបន់៖** ទីផ្សារដំឡូងមីនៅអាស៊ី បានបង្កើតខ្សែសង្វាក់តម្លៃក្នុងតំបន់ ដែលប្រទេសកម្ពុជាបានដាំដុះ ប្រមូលផល និងពុះជ្រៀក ហាលសំងួត ខណៈដែលប្រទេសជិតខាងមានឥទ្ធិពលលើទីផ្សារ និងការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម អនុវត្តតួនាទីនៃការកែច្នៃ ការរក្សាទុក និងការនាំចេញ។ ទោះបីជាទំហំផលិតកម្មត្រូវបានគេចាត់ថ្នាក់នៅលំដាប់ទីបួនក្នុងតំបន់ និងលំដាប់ទីប្រាំបីនៅលើពិភពលោកក៏ដោយ ក៏ប្រទេស

---

[2] របាយការណ៍វិភាគស្តីពីឧស្សាហកម្មដំឡូងមី (២០១៧), ASCS-Radius for its client, Green Leader Co. Ltd.

កម្ពុជា មិនទាន់ត្រូវបានគេស្គាល់ច្បាស់នៅក្នុងទីផ្សារសកលលោកនោះទេ កម្ពុជាគ្រាន់តែបានបំពេញតម្រូវការទីផ្សារ ដោយស្ងៀមស្ងាត់ក្នុងនាមជាអ្នកផ្គត់ផ្គង់ និងជាអ្នកទទួលយកនូវតម្លៃតូចតាច។

ដំឡូងមី គឺជាដំណាំពាណិជ្ជកម្ម ហើយមិនមែនជាអាហារមានស្ថិរភាព សម្រាប់ប្រជាជនកម្ពុជានោះទេ ផ្ទុយទៅនឹងប្រជាជនឥណ្ឌូនេស៊ី ប្រជាជនឥណ្ឌា ប្រជាជនអាហ្វ្រិក និងជនជាតិអាមេរិកឡាទីនមួយចំនួន។ ដំឡូងមី ត្រូវបានគេដាំដុះសម្រាប់ការនាំចេញ ហើយមានបរិមាណតិចតួចប៉ុណ្ណោះ ត្រូវបានគេប្រើប្រាស់សម្រាប់ជាអាហារ និងចំណីនៅក្នុងប្រទេស។ អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ដំឡូងមី ត្រូវបានគេនាំចេញក្នុងទម្រង់ជាវត្ថុធាតុដើម ដែលក្រោយមកត្រូវបានគេកែច្នៃទៅជាម្សៅ ក៏ដូចជាបន្ទះហាលស្ងួត ដែលជាធាតុផ្សំនៃចំណីសត្វនៅប្រទេសវៀតណាម និងផលិតតេអេតាណុលនៅប្រទេសថៃឡង់ដ៏។ បន្ថែមទៅលើផលដំឡូងមីរបស់ខ្លួន ប្រទេសជិតខាងទាំងពីរនេះបាននាំចេញផលិតផលដំឡូងមីទាំងនេះបន្តទៀតទៅកាន់ប្រទេសចិន។ ការនាំចេញដោយផ្ទាល់ពីកម្ពុជាទៅចិនមានទំហំតិចតួច ហើយមានតម្លៃត្រឹមតែ ១៥,៥ លានដុល្លារអាមេរិក ឬ ៨១,៤៩៧ តោននៃចំណិតដំឡូងមីក្រៀម និង ១០,៥ លានដុល្លារអាមេរិក ឬ ៣០,៩៣៧ តោនម្សៅមី នៅឆ្នាំ ២០១៦[3]។ រហូតមកទល់ពេលនេះ បរិមាណនៃការនាំចេញមិនទាន់មានការកើនឡើងគួរឱ្យកត់សម្គាល់នោះទេ។

## ទស្សនៈវិស័យទីផ្សារ

ដំឡូងមី ត្រូវបានគេដាំដុះនៅក្នុងប្រទេសច្រើនជាង ៩០ នៅតំបន់អាហ្វ្រិក អាមេរិកឡាទីន និងអាស៊ី។ វាគឺជាដំណាំសំខាន់បំផុតបន្ទាប់ពីអង្ករ ពោត និងស្រូវសាឡី និងបានផ្តល់ជាចំណីអាហារដល់មនុស្ស ៧៧០ លាននាក់។ ផលិតកម្មដំឡូងមីពិភពលោកបានកើនឡើង ២,៥% រវាងឆ្នាំ ២០០៩-២០១៦ ហើយបានឈានដល់ ២៨០ លានតោន ក្នុងឆ្នាំ២០១៦[4]។

ក្នុងរយៈពេល ២ ឆ្នាំកន្លងមកនេះ ពាណិជ្ជកម្មដំឡូងមីសកលលោកមានភាពយឺតយ៉ាវ ដោយសារមានការធ្លាក់ថ្លៃក្នុងដំណាំម្សៅដទៃទៀត ជាពិសេស ពោត និងស្រូវសាលី។ ការចំណាយលើផលិតកម្មដំឡូងមី និងជម្រើសជំនួសមានលក្ខណៈតូចចង្អៀត ដូច្នេះនាំឲ្យការប្រកួតប្រជែងលើផលិតផលដំឡូងមីបានថយចុះ។ ឧស្សាហកម្មក្នុងប្រទេសជាច្រើនបានឆ្លើយតបដោយការផ្លាស់ប្តូរទៅប្រើប្រាស់សម្ភារៈវត្ថុធាតុដើមជំនួសដែលមានតម្លៃថោកជាង។

ការផ្លាស់ប្តូរគោលនយោបាយកសិកម្មរបស់ប្រទេសចិន ក៏ផ្តល់ផលវិបាកធ្ងន់ធ្ងរចំពោះតម្លៃដំឡូងមី។ ការដកចេញនូវការឧបត្ថម្ភធនលើផលិតកម្មពោត និងការបញ្ចេញស្តុកពោតនៅក្នុងប្រទេសចិន ក្នុងរដូវកំពុងដាំដុះឆ្នាំ ២០១៦/២០១៧ បណ្តាលឱ្យតម្លៃពោតធ្លាក់ចុះពី ៣៦០ ទៅ ២០០ ដុល្លារក្នុងមួយតោន។ ប្រការនេះ បានជំរុញឱ្យតម្លៃដំឡូងមីនៅក្នុងតំបន់អាស៊ានធ្លាក់ចុះយ៉ាងខ្លាំង (១៦០ ដុល្លារក្នុងមួយតោន សម្រាប់ចំណិតដំឡូងមីស្ងួត

---

[3] ផែនទីពាណិជ្ជកម្ម ITC, ទិន្នន័យដកស្រង់ក្នុងខែ មិនា ឆ្នាំ ២០១៨

[4] ទីផ្សារម្សៅដំឡូងមីរបស់ IMARC (2017): និន្នាការសកល ចែករំលែក ទំហំ កំណើន ឱកាស និងការព្យាករណ៍ ២០១៧-២៣, www.imarcgroup.com

និង ៣២០ ដុល្លារក្នុងមួយតោនសម្រាប់ម្សៅដំឡូងមី)។ ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ តម្លៃដំឡូងមីបានកើនឡើង ពីកម្រិតទាបបំផុតរបស់ខ្លួននៅឆ្នាំ២០១៦/២០១៧ ដល់កម្រិតខ្ពស់ដែលមិនធ្លាប់បានឃើញពីមុនមក ចាប់តាំងពីវិបត្តិសត្វល្អិតស៊ីដំណាំក្នុងឆ្នាំ២០១០។ កង្វះខាតការផ្គត់ផ្គង់ គឺជាកត្តាចម្បងជំរុញឱ្យតម្លៃកើនឡើង ដោយសារតែការកាត់បន្ថយតំបន់ដាំដុះ ទឹកជំនន់នៅប្រទេសថៃ និងជំងឺនៅប្រទេសវៀតណាម និងកម្ពុជា[5]។ តម្លៃនេះ នឹងមាននិន្នាការធ្លាក់ចុះ ចាប់ពីពេលនេះរហូតដល់រដូវប្រមូលផលជាថ្មីនៅឆ្នាំ២០១៨/២០១៩។

បើពិនិត្យមើលទីផ្សារដំឡូងមីសកលលោក ប្រទេសចិននៅតែ និងបន្តជាអ្នកទិញដ៏ធំជាងគេបំផុតនូវផលិតផលដំឡូងមី និងម្សៅមីពីតំបន់អាស៊ីអាគ្នេយ៍ដែលមានចំនួន ៧៧ ភាគរយនៃទីផ្សារពិភពលោកនៅឆ្នាំ២០១៦។ បើទោះបីជាប្រទេសចិន បានឈានដល់សមត្ថភាពផលិតកម្មពោតបានគ្រប់គ្រាន់ដោយខ្លួនឯងក៏ដោយ ប្រទេសចិនក៏នៅរំពឹងថា នឹងពឹងផ្អែកទៅលើទីផ្សារគ្រាប់ធញ្ញជាតិសកលលោកបន្តទៀត ដើម្បីធានាដល់ការផ្គត់ផ្គង់របស់ខ្លួន (ព្រោះថាផលិតកម្មពោត គឺមានភាពងាយរងគ្រោះនឹងអាកាសធាតុ) និងដើម្បីធានាថាប្រជាពលរដ្ឋដ៏ច្រើនរបស់ខ្លួនមានអាហារបរិភោគគ្រប់គ្រាន់។ គួរឲ្យកត់សម្គាល់ផងដែរថា មានសេចក្តីប្រកាសនាពេលថ្មីៗនេះស្តីអំពីការផ្តល់អាណត្តិ E10 នៅទូទាំងប្រទេសចិន គឺជាសញ្ញាមួយបង្ហាញថា សម្ភារវត្ថុធាតុដើម និងសមត្ថភាពចម្ការ គួរតែត្រូវបានបង្កើន ដើម្បីពង្រឹងការអនុវត្តគោលនយោបាយនេះ[6]។

ម្សៅដំឡូងមី មាន ៨ ភាគរយ នៃផលិតកម្មម្សៅធញ្ញជាតិពិភពលោកសរុប។ ទីផ្សារពិភពលោក បានឈានដល់បរិមាណ ៦ លានតោនដែលបានចុះបញ្ជីជាអត្រាកំណើនប្រចាំឆ្នាំសរុប (CAGR) ២,២% ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៦។ តម្រូវការម្សៅដំឡូងមីសកលលោក ត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងកម្រិត CAGR ១,៩% រវាងឆ្នាំ ២០១៧ និង ២០២២ ដែលនឹងឈានដល់ ៧,៤ លានតោននៅត្រឹមឆ្នាំ២០២២[7]។ ផលិតផលដំឡូងមី កំពុងត្រូវបានគេប្រើប្រាស់ក្នុងការផលិតសារជាតុផ្អែម/បង្អែម ជាតុបន្ថែមធ្វើឲ្យខាប់ និងអាហារបន្ថែម ព្រមទាំងជាតុផ្សំសកម្មនៅក្នុងអាហារជាច្រើនមុខផងដែរ។ ម្សៅដំឡូងមី ក៏មានការប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងឧស្សាហកម្មផ្សេងទៀត ដូចជា ការផលិតឱសថ ក្រដាស ផលិតផលវាយក័ណ្ឌ អាហារនិងភេសជ្ជៈកែច្នៃ។

កាកសំណល់ម្សៅ ផ្តល់ឱកាសជាច្រើន ដើម្បីបង្កើតនូវអនុផល និងជាតុផ្សំផ្សេងៗទៀត។ ទាំងនេះ រួមបញ្ចូលនូវគ្រឿងផ្សំក្នុងចំណីសត្វ (ជាទូទៅជាសំណល់ពីដំឡូងមី) ជី ឬជីវឥន្ធនៈ រួមទាំងគ្រាប់ ឬជីវឧស្ម័ន។ ខណៈពេលដែលសមត្ថភាពផលិតម្សៅមី បានកើនឡើងនៅកម្ពុជា ទាំងបរិមាណ និងតម្លៃនៃសំណល់នឹងកើនឡើង ហើយនឹងមានឱកាសអភិវឌ្ឍន៍អនុផលម្សៅមី ទាំងសម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ។

---

[5] ទីផ្សារដំឡូងមី CIAT (២០១៨): ខ្សែសង្វាក់តម្លៃ និងជីវភាពរស់នៅនៅអាស៊ី: នៅពេលដែលភាពប្រាកដប្រជា គឺជាភាពច្បាស់លាស់តែមួយគត់ Cotonou, Benin ។

[6] ការវិភាគ: "អាណត្តិ Ethanol E១០ នៅទូទាំងប្រទេសចិនប្រឈមនឹងឧបសគ្គ" ដែលបានទាញយកពី https://www.patts.com/latest-news/agriculture / signapore / analysis-chinas-nationwide-e10-ethanol -mandate-26808971 ។

[7] ទីផ្សារម្សៅដំឡូងមីរបស់ IMARC (2017): និន្នាការសកល ចែករំលែក ទំហំ កំណើន ឱកាស និងការព្យាករណ៍ ២០១៧-២២, www.imarcgroup.com

អេតាណុល ត្រូវបានគេមើលឃើញថា ជាផលិតផលដ៏មានសក្តានុពលសម្រាប់ប្រទេសកម្ពុជា។ ទោះបីជាដូច្នេះក្តី តម្លៃប្រេងកើនឡើងខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កំពុងធ្វើឱ្យអ្នកកែច្នៃអេតាណុលនៅជុំវិញពិភពលោកកំពុងជួបការលំបាកក្នុងការស្វែងរកប្រាក់ចំណេញ។ អេតាណុល កែច្នៃពីដំឡូងមីរបស់ប្រទេសកម្ពុជាកំពុងប្រឈមនឹងការប្រកួតប្រជែងដោយផ្ទាល់ជាមួយអេតាណុល កែច្នៃពីពោត ឬអំពៅពីសហរដ្ឋអាមេរិក ឬប្រទេសប្រេស៊ីល ប្រសិនបើធ្វើការនាំចេញទៅកាន់ទីផ្សារពិភពលោក ដូចជា ចិន ឥណ្ឌា កូរ៉េ ជប៉ុន និងបណ្តាប្រទេសសហភាពអឺរ៉ុប។ មានឱកាសសម្រាប់ការប្រើប្រាស់អេតាណុលនៅក្នុងប្រទេសកម្ពុជាផងដែរ (ដូចជា ការបញ្ចូលអេតាណុលដែលបានកែច្នៃហើយនៅក្នុងប្រទេសជាមួយប្រេងសាំងដែលបាននាំចូល ដើម្បីបង្កើតជាតិហ្គាសដែលមានតម្លៃថោកជាង) និងផលិតជាភេសជ្ជៈ (គ្រឿងស្រវឹង/អាកុល)។

ដើម្បីឱ្យមាននិរន្តរភាព ដំឡូងមី គួរតែត្រូវបានផ្លាស់ប្តូរឲ្យទៅជាផលិតផលចុងក្រោយដែលទីផ្សារមានលក្ខណៈចម្រុះ និងតម្លៃអាស្រ័យលើខ្សែសង្វាក់តម្លៃនីមួយៗ។ ការផ្តោតលើទីផ្សារក្នុងស្រុក គឺជាជម្រើសមួយដែលត្រូវស្វែងរក ព្រោះតម្លៃនៃផលិតផល អាចមានការប្រកួតប្រជែងជាមួយនឹងផលិតផលបរទេសដែលមានតម្លៃថ្លៃ ក្នុងការនាំចូលមកប្រទេសកម្ពុជា។ ឧទាហរណ៍ នៅក្នុងប្រទេសនីហ្សេរីយ៉ា ម្សៅដំឡូងមី ត្រូវបានគេកំណត់អាណត្តិ ឲ្យលាយបញ្ចូលជាមួយស្រូវសាឡី យ៉ាងហោចណាស់ ១០ ភាគរយ ដើម្បីកាត់បន្ថយការនាំចូលស្រូវសាឡីដែលមានតម្លៃថ្លៃរាប់លានដុល្លារដែលប្រទេសត្រូវចំណាយ[8]។ ចំណិតដំឡូងមីក្រៀម និងស្លឹកដំឡូងមី ក្នុងអត្រា ១ភាគ៤ ត្រូវបានគេរកឃើញដែលបានជំនួសពោតនៅក្នុងចំណីមាន់ទា និងបានកាត់បន្ថយការចំណាយលើចំណីអាហារ ដោយគ្មានការបង្កគ្រោះថ្នាក់ដល់ការឡើងទម្ងន់ ឬផលិតកម្មស៊ុត[9] នោះឡើយ។ នៅក្នុងប្រទេសឥណ្ឌូណេស៊ី ការស្រាវជ្រាវបានបង្ហាញថា មីកញ្ចប់កែច្នៃពីម្សៅដំឡូងមី មាន ៨០ ភាគរយ ដូចគ្នាជាមួយនឹងមីកញ្ចប់ធ្វើពីម្សៅស្រូវសាលី[10]។ នៅប្រទេសម៉ូសំប៊ិក ដំឡូងមី ត្រូវបានគេប្រើប្រាស់ ដើម្បីផលិតស្រាបៀរជំនួសឲ្យការនាំចូលស្រូវ[11]។ ក្រុមហ៊ុនអាមេរិកមួយ បានផលិតសារជាតុផ្អែមពីដំឡូងមីជំនួសឱ្យស្ករអំពៅ។ វាមានសុខភាពល្អជាង ដោយសារតែដំឡូងមីគ្មានសារជាតុ fructose និង gluten ហើយមានកម្រិតកាឡូរីទាបជាង[12]។

ដំឡូងមី មានលក្ខណៈពិសេស ដោយសារ វាគ្មានជាតុ gluten គ្មានជាតុ GMO និងមានប្រូតេអ៊ីនទាប។ ប្រការនេះ បង្កើតបាននូវទីផ្សារពិសេស សម្រាប់ផលិតផលមានមូលដ្ឋានលើដំឡូងមី ដូច្នេះ នាំឲ្យគ្មានការប្រកួតប្រជែងជាមួយដំណាំជំនួស ដូចជា ពោត ស្រូវសាលី អង្ករ និងដំឡូងបារាំងឡើយ។ មានអ្នកទិញមានឆន្ទៈក្នុងការបង់ថ្លៃសមរម្យសម្រាប់ផលិតផលមានមូលដ្ឋានលើដំឡូងមីដែលមានលក្ខណៈសរីរាង្គ (ទាំងម្សៅ និងផលិតផលពី

---

[8] លោក Elijah Ige Ohimain (២០១៤) ការរំពឹងទុក និងបញ្ហាប្រឈមនៃការដាក់បញ្ចូលដំឡូងទៅក្នុងគោលនយោបាយនំប៉័ងស្រូវនៅក្នុងប្រទេសនីហ្សេរីយ៉ា អង្គភាពស្រាវជ្រាវគោលនយោបាយឧស្សាហកម្ម និងអាហារ នាយកដ្ឋានវិទ្យាសាស្ត្រជីវសាស្ត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យ Niger Delta។

[9] http://www.cassavabiz.org/postharvest/lvstock_1.htm

10 Akhmad Zainal Abidin (ឆ្នាំ ២០១៣) ការអភិវឌ្ឍមីកញ្ចប់ដោយប្រើម្សៅដំឡូងមី វិទ្យាស្ថានបច្ចេក Bandung ។

[11] Agence France-Presse (២០១៧) 'លើសពីស្រូវអង្ករ: ការផលិតស្រាបៀរពីផលិតផលដំឡូងបង្កការភ្ញាក់ផ្អើលនៅលើទីផ្សារ' ។

[12] Madhava, ដំឡូងមីសរីរាង្គ ទាញយកពី www.madhavasweenteners.com ។

ដំឡូងមី)។ ទោះជាយ៉ាងណាក្តី ការប្រកួតប្រជែងដ៏ខ្លាំងក្លាសម្រាប់ទីផ្សារ និងការបង្កើតប្រព័ន្ធអនុលោមផលិតផលដំឡូងមីសរីរាង្គ គឺជាដំណើរការដែលមានតម្លៃខ្ពស់ និងប្រើប្រាស់ពេលវេលាយូរ សម្រាប់សហគមន៍ ឬសហគ្រាសខ្នាតតូច និង មធ្យម។ សម្រាប់ម្សៅដំឡូងមីតែមួយមុខ មានតម្រូវការកើនឡើង ១០០ ដង ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ គឺពី ៦០ តោន នៅឆ្នាំ២០០៧ ដល់ ៦០០០០ តោន នៅឆ្នាំ២០១៧[13]។

ការរីកចម្រើននៃពាណិជ្ជកម្មដំឡូងមី មានភាពអំណោយផល ព្រោះដំឡូងមី នៅតែមានការប្រកួតប្រជែងជាមួយពោត និងដំណាំជំនួសផ្សេងៗទៀតដែលជាប្រភពនៃម្សៅធញ្ញជាតិ។ នៅក្នុងប្រទេសចិន និងតំបន់អាស៊ីមានកង្វះជាតិកាបូអ៊ីដ្រាត ដែលត្រូវបានលុបបំបាត់ដោយមុខងារដ៏ប្រពៃនៃខ្សែសង្វាក់ផ្គត់ផ្គង់ដំឡូងមីក្នុងតំបន់។ ការដកចេញនូវតម្លៃនៃការឧបត្ថម្ភធន បានកាត់បន្ថយតម្លៃពោតនៅប្រទេសចិន និងបានបន្ទាបតម្លៃដំឡូងមីដែលបាននាំចូលទៅប្រទេសនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ប៉ុន្តែគេរំពឹងថា ផលប៉ះពាល់នេះ នឹងថយចុះនាពេលអនាគត។ នៅក្នុងសហភាពអឺរ៉ុប ម្សៅដំឡូង បានទទួលផលប្រយោជន៍ពីការគាំទ្រផ្នែកស្ថាប័នគួរឲ្យកត់សម្គាល់ ហើយប្រការនេះ គឺមានមូលដ្ឋានពីអតិថិជនដែលមានភក្ដីភាព ក្នុងចំណោមអ្នកផលិតម្រេច និងម្ហូបអាហារ ដូច្នេះពួកគេ ទទួលបាននូវការការពារយ៉ាងខ្ពស់។ ដូច្នេះ អនាគតនៃដំឡូងមី ត្រូវពឹងផ្អែកលើសមត្ថភាពរបស់ខ្លួនក្នុងការរក្សាការប្រកួតប្រជែងជាមួយផលិតផលពោត និងដំណាំម្សៅជំនួសដទៃទៀត ដែលកំពុងដាំដុះនៅតាមតំបន់ផ្សេងៗគ្នាក្នុងពិភពលោក អាស្រ័យលើគុណភាពម្សៅ តម្លៃ លក្ខណៈពិសេស និងការផ្គត់ផ្គង់ដែលអាចជឿទុកចិត្តបាន។

## ចក្ខុវិស័យ និងទិសដៅយុទ្ធសាស្ត្រ

ដោយទទួលស្គាល់បញ្ហាប្រឈមនៃខ្សែសង្វាក់តម្លៃដំឡូងមីបច្ចុប្បន្ន និងឱកាសទីផ្សារដែលកំពុងងើបឡើង រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែធ្វើអន្តរាគមន៍ តាមរយៈការបង្កើតចក្ខុវិស័យ និងវិធានការគោលនយោបាយជាក់ស្តែងទៅក្នុងសកម្មភាពដើម្បីដឹកនាំអភិវឌ្ឍន៍វិស័យនេះ នៅក្នុងក្របខ័ណ្ឌផលិតកម្មដឹកនាំដោយទីផ្សារប្រកបដោយនិរន្តរភាព។

រាជរដ្ឋាភិបាលកម្ពុជា មានគោលបំណងដាក់ទីតាំងកម្ពុជាជាមជ្ឈមណ្ឌលនៃឧស្សាហកម្មកែច្នៃដំឡូងមី និងជាអ្នកផ្គត់ផ្គង់ផលិតផលដំឡូងមីដែលអាចជឿទុកចិត្តបានសម្រាប់ទីផ្សារសកលលោក។

ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់គោលដៅនាំចេញម្សៅដំឡូងមី ចំនួន ០,៥លានតោន (ម្សៅកែច្នៃ និងមិនទាន់កែច្នៃ) ទៅកាន់ទីផ្សារចម្រុះ និងចំនួន ១០០០ លានតោននៃផលិតផលដំឡូងមីដែលមានបុព្វលាភខ្ពស់ (ម្សៅ និងផលិតផលដំឡូងមីសរីរាង្គ) សម្រាប់ទីផ្សារពិសេស។ រាជរដ្ឋាភិបាលកម្ពុជាក៏បានលើកកម្ពស់ការប្រើប្រាស់អនុផល និងសំណល់ដំឡូងមី សម្រាប់ចំណីសត្វ និងជី ជាធាតុចូលដែលមានតម្លៃថោកសម្រាប់កសិករកម្ពុជា។

ដើម្បីសម្រេចបាននូវគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ទិសដៅយុទ្ធសាស្ត្រសំខាន់ៗចំនួនបីគឺ៖

---

[13] មជ្ឈមណ្ឌលសម្រាប់បច្ចេកវិទ្យាគ្រប់គ្រងទី ៧ នៃម្សៅដំឡូងមីនៅពិភពអាស៊ី ថ្ងៃទី ២៣-២៥ ខែ មករា ឆ្នាំ ២០១៨ សៀមរាប។

- ផ្លាស់ប្តូរពីផលិតកម្មដំឡូងមីតាមលក្ខណៈគ្រួសារ ទៅជាផលិតកម្មបែបពាណិជ្ជកម្ម ដែលកសិករនឹងទទួលបានផលចំណេញច្រើនជាង ក្នុងការបង្កើនបង្កើតប្រាក់ចំណូល ក្នុងបរិបទតម្លៃ ការប្រើប្រាស់ដីប្រកបដោយនិរន្តរភាពនិងកសិកម្មវៃឆ្លាតធន់នឹងអាកាសធាតុ។
- គាំទ្រដល់អ្នកសកម្មកែច្នៃផលិតផលដំឡូងមី និងទាក់ទាញការវិនិយោគ ដើម្បីបង្កើតផលិតផលផ្អែកលើដំឡូងមីដែលមានតម្លៃបន្ថែមដើម្បីផ្គត់ផ្គង់ដល់ទីផ្សារចម្រុះ។
- បង្កើនការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម តាមរយៈការផ្លាស់ប្តូរពីការទទួលបាននូវលទ្ធភាពទីផ្សារ ទៅរកវត្តមានទីផ្សារ ការធ្វើឲ្យប្រសើរឡើងនូវការសម្របសម្រួលពាណិជ្ជកម្ម និងការកាត់បន្ថយចំណាយពាក់ព័ន្ធនឹងពាណិជ្ជកម្ម។

រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តយកនូវអភិក្រមចំនួនបី ដែលគ្រប់បណ្តាញនៃខ្សែសង្វាក់តម្លៃដំឡូងមីត្រូវបាន បង្កើតឡើងក្នុងពេលតែមួយ នៅក្នុងវេទិកានៃវិស័យតែមួយ៖

- **ផលិតកម្មផ្អែកលើទីផ្សារ៖** ទីផ្សារនានា ត្រូវបានកំណត់ជាមុន ហើយបន្ទាប់មកខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវបានរៀបចំឲ្យស្របគ្នា។ តួអង្គសំខាន់ៗ ដូចជា កសិករ និងអ្នកកែច្នៃ ត្រូវបានសម្របសម្រួលឲ្យធ្វើការរួមគ្នា តាមរយៈការធ្វើកសិដ្ឋានតាមកិច្ចសន្យា តាមគ្រោងការណ៍ដែលមានកំណើនផលិតផល និងតាមយន្តការដែលមានខ្សែសង្វាក់ផ្គត់ផ្គង់អាចអនុវត្តន៍ទៅបាន។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ ត្រូវបានបង្កើតឡើង ហើយផែនការវិនិយោគ ត្រូវបានតម្រែតម្រង់គ្នារវាងតួអង្គសំខាន់ៗក្នុងខ្សែសង្វាក់តម្លៃ ក្នុងតំបន់របស់ពួកគេ ដើម្បីបង្កើនប្រសិទ្ធភាពខ្សែសង្វាក់ផលិតកម្ម។ គោលដៅនានា ត្រូវបានកំណត់ឧទាហរណ៍ប្រតិទិនដំណាំ ការបង្កើនទិន្នផល ការកាត់បន្ថយការចំណាយ និងការធានាគុណភាព។ ការវិនិយោគសាធារណៈ (រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍) ផ្តោតលើការអភិវឌ្ឍដែលវិស័យឯកជនបានធ្វើការវិនិយោគ ហើយកសិករដាំដុះដំឡូងមី។

- **ផលិតកម្មបែបពាណិជ្ជកម្ម៖** ដំឡូងមី គឺជាប្រភេទដំណាំដែលការប្រែប្រួល ហើយកសិករ អាចផ្លាស់ប្តូរទៅដាំដុះដំណាំផ្សេងៗទៀត នៅពេលដែលទស្សនវិស័យរកប្រាក់ចំណេញ មិនមានភាពទាក់ទាញហើយគ្មានការសន្យាពីទីផ្សារ។ ការលើកកម្ពស់ផលចំណេញរបស់កសិករ ជាពិសេសសម្រាប់អ្នកដែលរស់នៅក្នុងតំបន់ផលិតកម្មដំឡូងមីសមស្រប គឺជាអាទិភាពមួយ ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ និងគាំទ្រដល់ផែនការអាជីវកម្មរយៈពេលវែងនៃឧស្សាហកម្មកែច្នៃ។

ការធ្វើពាណិជ្ជកម្មដំឡូងមី ត្រូវតែអមដោយការស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងការអភិវឌ្ឍប្រព័ន្ធផលិតកម្មក្នុងស្រុក។ បញ្ហាផលិតកម្មដែលនាំឱ្យមានការបាត់បង់ខាងសេដ្ឋកិច្ចត្រូវតែដោះស្រាយ ដូចជាជំងឺ សត្វល្អិត សត្វចង្រៃ ការអនុវត្តកសិកម្មដែលមិនមាននិរន្តរភាព ការហូរច្រោះដី ការប្រើប្រាស់សម្ភារដាំដុះគ្មានសុខភាព និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ នៅពេលតម្លៃពលកម្ម នៅតែកើនឡើងហើយតំបន់ជនបទភាគច្រើន ប្រឈមនឹងបញ្ហាកង្វះខាតកម្លាំងពលកម្ម យន្តកម្មកសិកម្ម គួរតែត្រូវបានលើកកម្ពស់ ដើម្បីជំនួសការងារដែលពឹងផ្អែកលើកម្លាំងពលកម្ម។ ទីផ្សារផ្តល់នូវធាតុចូលកសិកម្ម

គួរតែត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈការបង្កើនការយល់ដឹង និងការកំណត់ការទទួលខុសត្រូវសម្រាប់អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្មដើម្បីស្វែងរកប្រភព និងផ្គត់ផ្គង់ផលិតផលដែលមានគុណភាព និងណែនាំដល់អតិថិជនរបស់ពួកគេក្នុងការប្រើប្រាស់ផលិតផលឲ្យបានត្រឹមត្រូវ ដើម្បីសុវត្ថិភាព និងប្រសិទ្ធភាព។ គ្រោងការណ៍ហិរញ្ញវត្ថុ គួរតែត្រូវបានច្នៃប្រឌិតបង្កើតថ្មី ឆ្ពោះទៅរកការគាំទ្រជីវភាពរស់នៅរបស់កសិករខ្នាតតូចតាមរយៈការតម្រែតម្រង់ពួកគេជាមួយនឹងប្រតិទិននៃការផលិតដំឡូងមី ការការពារពួកគេដើម្បីជៀសវាងពីស្ថានភាពយ៉ាប់យឺនក្នុងការលក់ផលិតផល និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់កម្ចីប្រកបដោយផលិតភាព។

- **ការអភិវឌ្ឍឧស្សាហកម្ម៖** ការកែលម្អអ្នកកែច្នៃដែលមានស្រាប់ និងការទាក់ទាញការវិនិយោគនៅក្នុងទំហំសេដ្ឋកិច្ចមួយដែលត្រឹមត្រូវ គឺជាចំណុចចាប់ផ្តើមនៃការផ្លាស់ប្តូរវិស័យនេះ និងជំរុញខ្សែសង្វាក់តម្លៃដំឡូងមី។ ឧស្សាហកម្មកែច្នៃដំឡូងមី គួរតែមានសមត្ថភាពដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដូចអ្នកកែច្នៃបរទេសដែរ ក្នុងការបង្កើតផលិតផលឲ្យមានតម្លៃប្រកួតប្រជែង មានការទាក់ទាញគ្រប់តម្លៃទាំងអស់ក្នុងខ្សែសង្វាក់ផលិតកម្មដំឡូងមី និងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីគ្រប់គ្រងការបំពុល។

ឧស្សាហកម្មកែច្នៃដំឡូងមី គួរតែផ្សាភ្ជាប់ជាមួយវិស័យដែលពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើឱ្យមានការរីកចម្រើននៃសេដ្ឋកិច្ចមានរាងជារង្វង់ដែលផ្តល់អត្ថប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ដល់វិស័យឯកជន និងសហគមន៍មូលដ្ឋាន។ កាកសំណល់ដំឡូងមី អាចលាយជាមួយធញ្ញជាតិផ្សេងទៀត ដូចជា ពោត អង្ករជាដើម - ជាពិសេសសម្រាប់ថាមពល (កាឡូរី) ដូចជា - អាហារសណ្តែកសៀង ចំណីត្រី សម្រាប់ប្រូតេអ៊ីនដូចជា - គ្រឿងផ្សំផ្សេងៗទៀត ដើម្បីផលិតចំណីសត្វ សម្រាប់សត្វចិញ្ចឹមក្នុងស្រុក ដែលជាឱកាសបន្ថែមសម្រាប់ជំនួសឲ្យការនាំចូល។ យោងតាមស្ថិតិពីមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) កម្ពុជាបាននាំចូលចំណីសត្វដែលមានតម្លៃប្រមាណ ៦៣ លានដុល្លារ ក្នុងឆ្នាំ២០១៦ ជាចម្បងមកពីប្រទេសថៃឡង់ដ៏ និងវៀតណាម។

សំណល់ដំឡូងមី ក៏អាចត្រូវបានប្រើប្រាស់បំលែងឲ្យទៅជាជី ដើម្បីផ្គត់ផ្គង់ទីផ្សារផ្តល់ធាតុចូលកសិកម្ម ឬលក់ដោយផ្ទាល់ទៅឲ្យកសិករក្នុងតម្លៃទាបជាងជីដែលបាននាំចូល។ សំណល់រាវពីដំឡូងមី អាចត្រូវបានបំលែងទៅជាជីរសរីរាង្គ ដើម្បីអាចស្រោចស្រពកសិដ្ឋាននៅក្បែរៗ ហើយជីវឧស្ម័ន ក៏អាចត្រូវបានបំលែងពីម្សៅដំឡូងមីស្ងួត ដើម្បីបង្កើតអគ្គិសនីសម្រាប់បម្រើឲ្យរោងចក្រ។ នៅប្រទេសថៃឡង់ដ៏ ទឹកដែលមិនបានប្រើប្រាស់ ហើយអគ្គិសនីដែលនៅសល់ពីរោងចក្រផលិតម្សៅមី ឬអេតាណុល ត្រូវបានផ្តល់ឲ្យ ឬលក់ទៅឱ្យសហគមន៍ក្នុងតម្លៃថោក ដែលជាការលើកទឹកចិត្តក្នុងការផ្គត់ផ្គង់ដំឡូងមីរបស់ពួកគេ។ ម៉្យាងទៀត ដំឡូងមី មានផ្ទុកសារជាតុស្យានីដអ៊ីដ្រូសែន (HCN) ខ្ពស់ ដូច្នេះ ការបំពុលពីសារជាតុនេះ គួរតែត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យឲ្យបានត្រឹមត្រូវនៅគ្រប់ដំណាក់កាលនៃការកែច្នៃទាំងអស់ ដើម្បីការពារបរិស្ថានកសិកម្ម ជីវចម្រុះ និងសុខុមាលភាពសហគមន៍។ ផលចំណេញផ្នែកសេដ្ឋកិច្ចពីការកែច្នៃដំឡូងមី

មិនគួរជាការផ្លាស់ប្តូរសម្រាប់សរីរាង្គមានជីវិត ឬការសម្របសម្រួលណាមួយ សម្រាប់មនុស្សជំនាន់ក្រោយ នោះឡើយ។

## យុទ្ធសាស្ត្រដើម្បីសម្រេចបានគោលដៅនៃគោលនយោបាយនេះ

ដោយសារ ការអភិវឌ្ឍជំឡុងមី ត្រូវបានផ្សារភ្ជាប់ទៅនឹងវិស័យកសិកម្មទាំងមូល និងវេទិកាពាណិជ្ជកម្ម រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែតម្រែតម្រង់ការអភិវឌ្ឍវិស័យនេះ ជាមួយនឹងយុទ្ធសាស្ត្រជាតិ និងគោលនយោបាយពាក់ព័ន្ធនានា ដើម្បីបំពេញ និងជំនួសឲ្យគ្នាទៅវិញទៅមក សម្រាប់ប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍។ ផ្នែកអន្តរវិស័យ ដូចជា ការដឹកជញ្ជូន ភស្តុភា ហិរញ្ញវត្ថុ ថ្លៃអគ្គិសនី ការសម្រួលពាណិជ្ជកម្ម មធ្យោបាយគាំទ្រផ្នែកពាណិជ្ជកម្ម និងកម្លាំងពលកម្មជំនាញត្រូវបានដោះស្រាយនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ចម្រុះរួមមួយ។ គោលនយោបាយស្តីពី ដំឡូងមី គឺជាករណីគំរូដែលស្របគ្នា និងមានសុខដុមរមណីយកម្មជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រដទៃទៀត ដូចជា យុទ្ធសាស្ត្រចតុកោណថ្មី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ផែនការមេស្តីពីភស្តុភា យុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក និងគោលនយោបាយនាំចេញអង្ករ។

ហេតុមកដល់ពេលនេះ វិស័យនេះត្រូវបានបែកបាក់ ហើយត្រូវបានកាត់ផ្តាច់ក្នុងចំណោមអ្នកដើរតួសំខាន់ៗ។ មិនមានយន្តការ ឬរចនាសម្ព័ន្ធក្នុងវិស័យនេះ ដែលត្រូវបានបង្កើតឡើង ដើម្បីផ្សព្វផ្សាយព័ត៌មាន និងពិភាក្សាបញ្ហាសម្រាប់ការគាំទ្រឲ្យបានទាន់ពេលវេលា និងអន្តរាគមន៍ផ្អែកលើលទ្ធផលនោះឡើយ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូល និងផ្តល់អាទិភាពលើវិស័យដំឡូងមី ជារបៀបវារៈសំខាន់នៃវេទិការវាងរដ្ឋាភិបាល និងវិស័យឯកជន (G-PSF) និងជាវេទិកាដែលមានការពាក់ព័ន្ធកម្រិតខ្ពស់។ រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើត និងរៀបចំមូលដ្ឋានគ្រឹះក្នុងវិស័យនេះ ដើម្បីរួមបញ្ចូលតួអង្គសំខាន់ៗនៃខ្សែសង្វាក់តម្លៃទៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ច និងជួយបំពេញមុខងាររបស់ពួកគេ ក្នុងការដឹកនាំ ជួយសម្របសម្រួល និងតាមដាន វឌ្ឍនភាព ការអនុវត្ត និងសមិទ្ធផលនៃការអភិវឌ្ឍ។

រាជរដ្ឋាភិបាលកម្ពុជា បន្តអនុវត្តកំណែទម្រង់ដែលទាក់ទងនឹងពាណិជ្ជកម្មដើម្បីលុបបំបាត់ការចំណាយមិនចាំបាច់រក្សាអត្ថប្រយោជន៍សំខាន់ៗ និងបង្កើតនូវតម្លៃបន្ថែម ដើម្បីបង្កើនការប្រកួតប្រជែងក្នុងវិស័យនេះ ដែលនឹងនាំឱ្យមានការផ្លាស់ប្តូរពីលទ្ធភាពទទួលបានទីផ្សារឆ្ពោះទៅរកវត្តមានរបស់ទីផ្សារវិញ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាអនុម័ត និងអនុវត្តវិធានការគោលនយោបាយ ដើម្បីបង្កើនផលចំណេញរបស់តួអង្គសំខាន់ៗនៃខ្សែសង្វាក់តម្លៃ ជាពិសេស កសិករ និងអ្នកកែច្នៃ តាមរយៈការជំរុញផលិតភាពបុគ្គល និងការតភ្ជាប់ជាមួយវិស័យពាក់ព័ន្ធទាំងខាងមុខ និងខាងក្រោយ ដើម្បីបង្កើនប្រសិទ្ធភាពនៃខ្សែសង្វាក់តម្លៃដំឡូងមី។ ដូច្នេះ តម្លៃនៃផលិតផលដំឡូងមីនឹងមានតម្លៃស្របគ្នាជាមួយតម្លៃអន្តរជាតិ ខណៈដែលតម្រូវការផ្នែកគុណភាព នឹងត្រូវបានបំពេញតាមតម្លៃដែលតួអង្គសំខាន់ៗនៃខ្សែសង្វាក់តម្លៃ អាចរកបានប្រាក់ចំណេញ។

ដើម្បីជំរុញការអភិវឌ្ឍវិស័យនេះក្នុងល្បឿនមួយដែលចង់បាន រាជរដ្ឋាភិបាលកម្ពុជា បានសហការជាមួយដៃគូអភិវឌ្ឍន៍ នឹងរៀបចំអនុវត្តគម្រោងនានាដែលបំពេញចន្លោះប្រហោងក្នុងវិស័យឯកជន និងការវិនិយោគរបស់កសិករ។ កិច្ចសហប្រតិបត្តិការនេះ គួរតែត្រូវបានធ្វើដោយប្រើប្រាស់គំរូនៃភាពជាដៃគូរវាងអ្នកផលិតសាធារណៈ និងឯកជន ដូច្នេះធនធានត្រូវបានប្រើប្រាស់ជាយុទ្ធសាស្ត្រ និងមុខងារ ត្រូវបានអនុវត្តស្របគ្នា ដើម្បីសម្រេចបាននូវគោលដៅរួម និងគោលដៅបុគ្គល។

## វិធានការគោលនយោបាយ

ដោយសារតម្លៃដំឡូងមី មានការប្រែប្រួល ខ្សែសង្វាក់តម្លៃ ត្រូវតែបានបង្កើតឡើងតាមរយៈការកសាងផលចំណេញនៅលើតម្លៃទាបបំផុតដែលបានកត់ត្រាជាច្រើនឆ្នាំកន្លងមក។ ផលចំណេញ នឹងត្រូវបានសម្រេចតាមរយៈការលើកកម្ពស់ផលិតភាពរបស់តួអង្គម្នាក់ៗ ការលើកកម្ពស់ការផ្សារភ្ជាប់គ្នារវាងខ្សែបណ្តោយ និងខ្សែទទឹង ដើម្បីដោះស្រាយបញ្ហាគ្មានប្រសិទ្ធភាពនៃខ្សែសង្វាក់តម្លៃ និងការកសាងប្រព័ន្ធមួយប្រកបដោយប្រសិទ្ធភាពក្នុងការធ្វើសមកាលកម្មវិស័យនេះជាមួយអន្តរវិស័យដើម្បីបង្កើនផលប្រយោជន៍ទៅវិញទៅមក។

***ផលិតភាពនៃផលិតកម្មដំឡូងមីនៅកម្ពុជា ត្រូវបានបង្កើនតាមរយៈការកែលម្អទិន្នផល និងការកាត់បន្ថយតម្លៃដោយគ្មានហានិភ័យដល់ប្រព័ន្ធអេកូឡូស៊ីកសិកម្ម៖***

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការសិក្សាលើតំបន់ដាំដុះដំឡូងមីជាទៀងទាត់ ដើម្បីកត់ត្រាទំហំផលិតកម្ម កំណត់តំបន់ តាមដានជីវជាតិរបស់ដី និងតាមដានតម្លៃផលិតកម្ម។ ផ្អែកលើការសិក្សាអង្កេតទាំងនេះ ខ្សែក្រវាត់ផលិតកម្មដំឡូងមី គួរតែត្រូវបានបង្កើតឡើង ដើម្បីលើកទឹកចិត្តដល់កសិករប្រើប្រាស់ដីសមស្របសម្រាប់ការដាំដុះដំឡូងមីឱ្យមានលក្ខណៈរស់រវើក និងដើម្បីទទួលបានអត្ថប្រយោជន៍ច្រើនទាំងខាងបរិស្ថាន និងសេដ្ឋកិច្ចសង្គម។ ខ្សែក្រវាត់ផលិតកម្មដំឡូងមី ត្រូវបានគេចាត់ទុកថា ជាឧបករណ៍កំណត់តំបន់មួយ ដើម្បីលើកកម្ពស់ និងគ្រប់គ្រងការដាំដុះប្រកបដោយនិរន្តរភាពនូវភាពចម្រុះនៃដំណាំដំឡូងមីឲ្យបានត្រឹមត្រូវ ដូច្នេះ ដំណាំនេះនឹងលូតលាស់បានសមស្រប ដើម្បីផ្គត់ផ្គង់ដល់អ្នកកែច្នៃស្របតាមលក្ខណៈជាក់លាក់របស់ផលិតផល។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈមន្ទីរកសិកម្មខេត្ត បានតាមដានរកមើលចរាចរនៃសម្ភារដាំដុះដំឡូងមីដែលនាំចូលពីបរទេស។ មន្ទីរកសិកម្មខេត្ត បានពិនិត្យលើគុណភាព និងវាយតម្លៃផ្នែកសុខភាព និងអនាម័យដើម្បីការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺនៅក្នុងប្រទេស និងដើម្បីកាត់បន្ថយការបាត់បង់ផ្នែកសេដ្ឋកិច្ចដែលអាចកើតមានសម្រាប់វិស័យនេះ។ ការគំរាមកំហែងដែលបានរកឃើញត្រូវបានដោះស្រាយតាមរយៈវិធានការអនាម័យ និងវិធានការណែនាំយ៉ាងតឹងរឹង និងតាមរយៈយន្តការត្រួតពិនិត្យដែលមានស្រាប់។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែចរចាជាមួយរដ្ឋាភិបាលនានាក្នុងតំបន់ ដើម្បីនាំចូលពូជដំឡូងមីដែលផ្តល់ទិន្នផលខ្ពស់ធន់នឹងជំងឺ ធន់នឹងអាកាសធាតុរាំងស្ងួត ដើម្បីធ្វើតេស្តនៅកម្ពុជា ហើយ

បន្ទាប់មកចែកចាយដល់កសិករ ប្រសិនបើពូជទាំងនោះសមស្របនឹងលក្ខខណ្ឌអាកាសធាតុ និងដីរបស់ប្រទេសកម្ពុជា។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំរុញឱ្យមានថ្នាលបណ្តុះដំឡូងមីបែបពាណិជ្ជកម្ម និងមជ្ឈមណ្ឌលពហុបច្ចេកទេសកាន់កាប់ដោយឯកជន ដើម្បីផលិត និងចែកចាយសម្ភារដាំដុះដែលមានសុខភាពល្អ ជាមួយនឹងពូជត្រឹមត្រូវដែលស្របតាមលក្ខណៈដីរបស់កសិករ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពិនិត្យតាមដាន និងវាយតម្លៃលើគុណភាពធាតុចូលកសិកម្ម (ដូចជា ជី ។ល។) ដែលកំពុងអនុវត្តចំពោះដំណាំដំឡូងមី ដើម្បីធានាប្រសិទ្ធភាពលើការកែលម្អទិន្នផល និងភាពស៊ីគ្នាជាមួយនឹងលក្ខខណ្ឌដី ដូច្នេះ វានឹងមានតម្លៃដល់ការវិនិយោគរបស់កសិករ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពិនិត្យតាមដាន និងធ្វើអធិការកិច្ចលើសត្វល្អិតចង្រៃ ជំងឺស្មៅ និងកត្តាអវិជ្ជមានដទៃទៀត ដែលប៉ះពាល់ដល់ផលិតកម្មដំឡូងមី។ ការគំរាមកំហែង និងហានិភ័យដែលបានកំណត់គួរតែត្រូវបានគ្រប់គ្រង និងកាត់បន្ថយតាមរយៈវិធានការសកម្មនាំមុខ ដើម្បីចៀសវាងការខាតបាត់បង់ផ្នែកសេដ្ឋកិច្ច។ ការទំនាក់ទំនង និងការផ្សព្វផ្សាយដល់មូលដ្ឋាន តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានបង្កើតឡើង ដើម្បីផ្សព្វផ្សាយព័ត៌មានដល់កសិករ អ្នកកែច្នៃ និងអ្នកពាក់ព័ន្ធទាំងអស់។
- ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវផ្តល់សេវាផ្សព្វផ្សាយ អំពីផលិតកម្មដំឡូងមីវៃឆ្លាត ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការអនុវត្តកសិកម្មល្អៗ ត្រូវបានបញ្ជ្រាបដល់កសិករ។ បច្ចេកវិទ្យា និងបច្ចេកទេសថ្មីដែលមានប្រសិទ្ធភាពខ្ពស់ និងសមស្របសម្រាប់កសិករដើម្បីបង្កើនផលិតភាពរបស់ពួកគេត្រូវបានស្វែងរកការសាកល្បង និងផ្សព្វផ្សាយ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែកែលម្អសេវាកម្មកសិកម្មឯកជន តាមរយៈការរៀបចំឱ្យមានគ្រឿងចក្រ ឬឧបករណ៍កសិកម្មដោយផ្ទាល់ជាក្រុម (ផ្លូវការ ឬមិនផ្លូវការ) ដើម្បីបង្កើនផលិតភាពរបស់ពួកគេ និងលើកកម្ពស់គុណភាពសេវាកម្ម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបណ្តុះបណ្តាលជំនាញបច្ចេកទេសទាក់ទងនឹងកសិដ្ឋាន និងជំនាញផ្នែកទន់ ដូច្នេះ ការងាររបស់ពួកគេនឹងអនុលោមទៅតាមការអនុវត្តកសិកម្មប្រកបដោយនិរន្តភាព ដែលនឹងនាំមកនូវទិន្នផលកើនឡើងនៅក្នុងតម្លៃមួយដែលអាចគ្រប់គ្រងបាន។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំកសិករដាំដំឡូងមី ជាក្រុមអ្នកផលិត ជាចង្កោម ជាកម្រង ឬជាសហករណ៍ ហើយធ្វើសមាហរណកម្មក្រុមកសិករផ្លូវការ និងមិនផ្លូវការទាំងនេះ ទៅក្នុងរចនាសម្ព័ន្ធសមូហភាព ស្របទៅតាមតំបន់ភូមិសាស្ត្រ បរិបទសេដ្ឋកិច្ច-សង្គម និងឆន្ទៈរបស់ពួកគេ ដែលជាចំណុចមួយនៃការភ្ជាប់បណ្តាញសេវាកម្មផ្សេងៗ និងការផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារ ក៏ដូចជាការតភ្ជាប់ជាមួយនឹងអ្នកកែច្នៃឯកជន។
- ជារៀងរាល់ឆ្នាំ ដើមរដូវកាលផលិតកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែរៀបចំទិវាដំឡូងមីដើម្បីកំណត់ និងផ្តល់រង្វាន់ដល់កសិករជើងឯក ដែលបង្ហាញពីភាពជាសហគ្រិន និងដើរតួជាគំរូ ដើម្បីជំរុញអ្នកដទៃ និងផ្សព្វផ្សាយការអនុវត្តកសិកម្មទំនើប បច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗដល់កសិករ។

*ការអភិវឌ្ឍវិស័យឯកជនឈានមុខគេ តាមរយៈការជួយកសិករឱ្យសម្រេចបាននូវកម្រិតសេដ្ឋកិច្ច និងការកាត់បន្ថយចំណាយអាជីវកម្ម ដើម្បីឱ្យពួកគេអាចប្រកួតប្រជែងជ្រៀតចូលទីផ្សារ៖*

- ក្រសួងពាណិជ្ជកម្ម តាមរយៈវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវពាណិជ្ជកម្ម គួរតែវិភាគ និងធ្វើបច្ចុប្បន្នភាពខ្សែសង្វាក់តម្លៃដំឡូងមីជាទៀងទាត់ ដោយពិនិត្យមើលនិន្នាការទីផ្សារ ការប្រកួតប្រជែងក្នុងតំបន់ និងរចនាសម្ព័ន្ធតម្លៃនៅកម្ពុជា។ ការសិក្សាទាំងនេះ ផ្តល់នូវធាតុចូលផ្អែកលើភស្តុតាង សម្រាប់កិច្ចពិភាក្សាគោលនយោបាយ ដូច្នេះវិធានការគោលនយោបាយអាចត្រូវកែប្រែ ឬបន្ថែមដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអភិវឌ្ឍវិស័យនេះដោយរលូន។
- ក្រុមប្រឹក្សាសម្រាប់ការអភិវឌ្ឍកម្ពុជា ដោយមានការគាំទ្រពីក្រុមការងារដំឡូងមី គួរបង្កើតយុទ្ធសាស្ត្រវិនិយោគដំឡូងមី និងធ្វើសកម្មភាពដើម្បីទាក់ទាញអ្នកវិនិយោគ ដូច្នេះសមត្ថភាពកែច្នៃដំឡូងមី នឹងត្រូវបានបង្កើនតាមការចាំបាច់ដើម្បីសម្រេចគោលដៅនាំចេញ។ ព័ត៌មានតាមវិស័យសំខាន់ៗ និងគោលការណ៍ណែនាំអំពីការវិនិយោគដំឡូងមីត្រូវបានបង្កើតឡើង និងមានលទ្ធភាពចូលប្រើប្រាស់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលមានលក្ខណៈងាយស្រួល និងមានប្រសិទ្ធភាព។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ការលើកទឹកចិត្តដល់អ្នកកែច្នៃ និងអ្នកនាំចេញផលិតផលដំឡូងមីផ្លូវការ និងអ្នកធ្វើអាជីវកម្មដទៃទៀតដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់កសិករ តាមរយៈការលើកលែង ឬកាត់បន្ថយពន្ធ ដូចជា ពន្ធលើប្រាក់ចំណូល និងពន្ធលើតម្លៃបន្ថែមជាដើម។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកាត់បន្ថយ ឬលើកលែងពន្ធលើផលិតផលដែលបានមកពីដំឡូងមីដើម្បីលើកទឹកចិត្តដល់ការកែច្នៃដំឡូងមីឱ្យទៅជាផលិតផលចុងក្រោយសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ។
- ក្រសួងរ៉ែ និងថាមពល ជាពិសេសអង្គភាពអគ្គិសនីកម្ពុជា ត្រូវតែផ្តល់អាទិភាព និងពន្លឿនការកាត់បន្ថយថ្លៃអគ្គិសនី និងធានាការផ្គត់ផ្គង់ដែលអាចទុកចិត្តបានសម្រាប់រោងចក្រកែច្នៃដំឡូងមី។ ដោយសារកាកសំណល់រាវពីដំឡូងមីអាចបង្កើតជីវឧស្ម័ន និងអាចបំលែងទៅជាអគ្គិសនី ក្រសួងរ៉ែ និងថាមពល ត្រូវលើកទឹកចិត្តឱ្យអ្នកកែច្នៃដំឡូងមី ធ្វើការវិនិយោគលើមធ្យោបាយផលិតជីវឧស្ម័ន តាមរយៈការគាំទ្រនីតិវិធីស្របច្បាប់ ការផ្តល់ការអនុញ្ញាត និងអនុលោមទៅតាមតម្រូវការនានា ព្រមទាំងការទិញថាមពលអគ្គិសនីដែលនៅសល់ក្នុងតម្លៃសមស្រប ឬការអនុញ្ញាតឱ្យមានការលក់របស់ខ្លួនដោយផ្ទាល់ទៅកាន់គ្រួសារដែលនៅជិតខាងតាមអត្រាដូចគ្នានឹងអ្នកផ្គត់ផ្គង់ឯកជនក្នុងស្រុក និង/ឬការលក់របស់រដ្ឋ។
- ក្រសួងបរិស្ថាន ត្រូវជួយដល់រោងចក្រកែច្នៃដំឡូងមី ដើម្បីប្រើប្រាស់បច្ចេកវិទ្យាគ្រប់គ្រងការបំពុលពីការកែច្នៃ និងបង្កើតតម្លៃពីកាកសំណល់ ដើម្បីធានាផលប៉ះពាល់ជាអប្បបរមាទៅលើសហគមន៍ អេកូឡូស៊ី និងជីវចម្រុះ។ ក្រសួងបរិស្ថាន ត្រូវតែកំណត់នីតិវិធីច្បាស់លាស់ និងគោលការណ៍ណែនាំសម្រាប់ការជ្រើសរើសទីតាំងកែច្នៃស្របតាមយុទ្ធសាស្ត្រវិនិយោគដំឡូងមីនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធានាថាទីតាំងទាំងនោះមិនស្ថិតនៅក្នុងតំបន់មានមនុស្សរស់នៅ ឬដែនជម្រកសត្វព្រៃដែលងាយប៉ះពាល់ និង/ឬតំបន់ការពារធម្មជាតិដទៃទៀត ហើយយ៉ាងហោចណាស់រោងចក្រកែច្នៃទាំងនោះត្រូវមានចម្ងាយ ៤០ គ.ម ពីតំបន់ទាំងនោះ។

- ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំវិស័យឯកជន រួមទាំងអ្នកនាំចេញ និងអ្នកកែច្នៃដែលពាក់ព័ន្ធ ក្នុងអាជីវកម្មដំឡូងមី តាមរយៈការបង្កើតសមាគមអាជីវកម្មថ្នាក់ជាតិ។ ច្បាប់ស្តីពីតួនាទី មុខងារ និងអាជ្ញាធររបស់សមាគមធុរកិច្ច ជាទូទៅ ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់តួនាទីសកម្មរបស់វិស័យឯកជននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា។
- ជារៀងរាល់ ២ ឆ្នាំម្តង ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំវេទិកា/សន្និសីទស្តីពីដំឡូងមី ដើម្បីលើកកម្ពស់ផលិតផលដំឡូងមីរបស់កម្ពុជា និងផ្សារភ្ជាប់វិស័យឯកជនទៅនឹងបណ្តាញពាណិជ្ជកម្មអន្តរជាតិ។
- ក្រសួងពាណិជ្ជកម្ម ត្រូវបង្កើតវេទិកាតាមអ៊ីធឺណិតពីធុរកិច្ចទៅធុរកិច្ច ដើម្បីភ្ជាប់វិស័យឯកជនកម្ពុជាជាមួយអ្នកទិញបរទេស និងជាផ្នែកវិស័យដើម្បីចែករំលែកព័ត៌មានអំពីដំឡូងមី។ កិច្ចការនេះ អាចប្រគល់ឱ្យសមាគមអាជីវកម្មដំឡូងមីដើម្បីគ្រប់គ្រង និងដំណើរការ។
- ក្រសួងពាណិជ្ជកម្ម គួរតែចរចាជាមួយរដ្ឋាភិបាលនៃប្រទេសនាំចេញគោលដៅនានា លើការលើកលែងពន្ធឬការកាត់បន្ថយ និងការសម្រួលពាណិជ្ជកម្ម ដើម្បីធានាដំណើរការនាំចេញដោយរលូនពីប្រទេសកម្ពុជា។ ក្រសួងពាណិជ្ជកម្ម គួរតែជួយសម្របសម្រួលកិច្ចព្រមព្រៀងពាណិជ្ជកម្មផងដែរប្រសិនបើមានការរៀបចំរវាងរដ្ឋាភិបាល និងរដ្ឋាភិបាលត្រូវបានគេតម្រូវ ឬគេចង់បាន។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរតែចរចាជាមួយរដ្ឋាភិបាលនៃប្រទេសនាំចេញគោលដៅ ដើម្បីលុបបំបាត់ឧបសគ្គ SPS ហើយប្រសិនបើចាំបាច់ត្រូវមានពិធីសារ SPS ដែលត្រូវបានចុះហត្ថលេខា និងប្រមូលការគាំទ្រដើម្បីកសាងសមត្ថភាពអំពីអនុលោមភាព SPS សម្រាប់អ្នកនាំចេញកម្ពុជា និងអ្នកពាក់ព័ន្ធ។ សេវា SPS សាធារណៈនិងឯកជន គួរតែត្រូវបានបង្កើនឡើង និងពង្រីកប្រសិនបើមានតម្រូវការ។
- វិទ្យាស្ថានស្តង់ដារកម្ពុជានៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម គួរបង្កើត និងធ្វើបច្ចុប្បន្នភាពស្តង់ដារផលិតផលតាមតម្រូវការ ដើម្បីលើកកម្ពស់ផលិតផលកែច្នៃពីដំឡូងមីកម្ពុជា និងគាំទ្រដល់អ្នកកែច្នៃដំឡូងមីដើម្បីទទួលបានវិញ្ញាបនបត្រ SPS និង/ឬវិញ្ញាបនបត្របញ្ជាក់គុណភាព ដែលតម្រូវដោយទីផ្សារ/អ្នកទិញ។

*ហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានបង្កើតឡើង ដើម្បីធ្វើឱ្យប្រព័ន្ធខ្សែសង្វាក់តម្លៃដំឡូងមី បំពេញមុខងារ ស្របតាមក្របខ័ណ្ឌផលិតកម្មផ្អែកលើទីផ្សារ និងផ្សារភ្ជាប់ជាមួយវិស័យពាក់ព័ន្ធដែលមានតម្លៃបន្ថែមទៀត ត្រូវបានបង្កើតឡើង និងចែកចាយទៅក្នុងសេដ្ឋកិច្ចជនបទ៖*

- រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានផលិតកម្មដំឡូងមីនៅតាមតំបន់រដ្ឋបាលរបស់ខ្លួន ត្រូវរួមបញ្ចូលដំឡូងមីក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងផែនការវិនិយោគរបស់ខ្លួន និងត្រូវសហការជាមួយសហគមន៍មូលដ្ឋានដើម្បីផ្តួចផ្តើមមូលនិធិក្នុងការកសាង និងកែលម្អផ្លូវថ្នល់សម្រាប់ផ្តល់លទ្ធភាពចូលទៅដល់កសិដ្ឋានពេញមួយឆ្នាំ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសហការជាមួយវិស័យឯកជន ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗក្នុងការកាត់បន្ថយ និង/ឬ រក្សាកុំឲ្យមានការបាត់បង់ផ្នែកសេដ្ឋកិច្ចក្នុងអំឡុងពេលប្រមូលផល និង

ក្រោយពេលប្រមូលផលពោលគឺ ត្រូវមានឃ្លាំងស្តុកខ្នាតតូច ឃ្លាំងស្តុកសមូហភាព ធនាគារដំឡូងមី ឬមជ្ឈមណ្ឌលពហុបំណងនៅទីតាំងផលិតកម្ម និងកែច្នៃជាយុទ្ធសាស្ត្រ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដើម្បីជួយដល់កសិករក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ដែលរងផលប៉ះពាល់ និងងាយរងគ្រោះ និងកសាងភាពធនរបស់ពួកគេ។ ទាំងនេះ រួមមានអាងស្តុកទឹក ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ប្រព័ន្ធបង្ហូរទឹកជាដើម។
- ធនាគារជាតិនៃកម្ពុជា ត្រូវពិនិត្យឡើងវិញលើគ្រោងការណ៍ហិរញ្ញវត្ថុបច្ចុប្បន្ន (កម្ចី) ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារពាណិជ្ជ កំពុងផ្តល់កម្ចីដល់កសិករ និងវិស័យឯកជន។ ប្រការនេះ គឺដើម្បីកំណត់ពីកង្វះខាត និងដើម្បីច្នៃបង្កើតគម្រោងថ្មីៗ ដែលតម្រែតម្រង់ស្របគ្នាទៅនឹងជីវភាពរបស់កសិករដាំដុះដំឡូងមីខណៈពេលស្របគ្នា ដែលតម្រូវឲ្យមានការលើកកម្ពស់ការប្រើប្រាស់ប្រាក់កម្ចីប្រកបដោយប្រសិទ្ធភាព។
- ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវចរចាជាមួយរដ្ឋាភិបាលនៃប្រទេសជិតខាង ដើម្បីកំណត់នីតិវិធីច្បាស់លាស់ សម្រាប់ការដឹកជញ្ជូនទំនិញដោយរលូន និងអាចព្យាករណ៍បានពីផលិតផលកម្ពុជាជាពិសេសសម្រាប់ផលិតផលដំឡូងមីតាមរយៈកំពង់ផែរបស់ពួកគេ។
- ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវពន្លឿនការបញ្ចប់ការសាងសង់ផ្លូវដែក និងការតភ្ជាប់ទៅតំបន់កែច្នៃដំឡូងមីសំខាន់ៗ ដូច្នេះផលិតផលដំឡូងមីអាចត្រូវបានដឹកជញ្ជូនដោយមធ្យោបាយនេះ។ ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវកំណត់តម្លៃខ្ពស់បំផុតក្នុងអត្រាមួយដែលរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយចំណាយដឹកជញ្ជូនផលិតផលដំឡូងមី ដែលអាចទទួលយកបានពីក្រុមហ៊ុនដឹកជញ្ជូនផ្លូវដែក។
- ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវតែយកចិត្តទុកដាក់ជាពិសេសចំពោះផលិតផលដំឡូងមី ដូចជាអង្ករដែរ នៅពេលដែលផលិតផលទាំងនេះមកដល់កំពង់ផែ ដូចជា ការកាត់បន្ថយថ្លៃបង់សេវាពាក់ព័ន្ធគ្រប់ប្រភេទ ការទូទាត់ភ្លាមៗ ការស្តុកទំនិញ និងសេវាលើកដាក់។ល។
- ក្រសួងមហាផ្ទៃ ជាពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គួរតែបង្កើតក្រុមការងារនៅក្នុងតំបន់រដ្ឋបាលរបស់ខ្លួន ដើម្បីពិនិត្យតាមដាន និងដោះស្រាយភាពមិនប្រក្រតី និងបណ្តឹងតវ៉ា ឧទាហរណ៍ ការប្រព្រឹត្តដោយអយុត្តិធម៌ ការអនុវត្តអសីលធម៌ ការលួចបន្លំ ការបង្កការលំបាក ការយកកម្រៃក្រៅផ្លូវការ។ល។
- ក្រសួងបរិស្ថាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ គួរតែតាមដានយ៉ាងជិតដល់នូវការបំពេញការងារនៃមជ្ឈមណ្ឌលកែច្នៃ និងរោងចក្រទាំងអស់លើការគ្រប់គ្រងបរិស្ថាន និងការកាត់បន្ថយហានិភ័យ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើនផលិតភាពរបស់ពលករនៅជនបទ តាមរយៈការបណ្តុះបណ្តាលនៅក្នុង និងក្រៅកសិដ្ឋាន ដើម្បីកែលម្អការបំពេញការងាររបស់ពួកគេ គុណភាពសេវា និងការប្រើប្រាស់បច្ចេកទេសកសិកម្មប្រកបដោយប្រសិទ្ធភាព។

**រយៈពេលវែង: ការប្រកួតប្រជែងក្នុងវិស័យនេះ ត្រូវបានដឹកនាំដោយភាពជាដៃគូរវាងផលិតករសាធារណៈ និងឯកជនប្រកបដោយប្រសិទ្ធភាព ដើម្បីផ្លាស់ប្តូរវិស័យនេះទៅជាឧស្សាហកម្មកែច្នៃស៊ីជម្រៅ៖**

- ក្រសួងពាណិជ្ជកម្ម ដោយសហការជាមួយវិស័យឯកជន គួរតែបង្កើតអង្គភាពស៊ើបអង្កេតទីផ្សារ ដើម្បីតាមដានទីផ្សារ និងផ្តល់នូវធាតុចូលផ្នែកយុទ្ធសាស្ត្រដល់គណៈកម្មាធិការដឹកនាំ ក្រសួងពាក់ព័ន្ធ និងតួអង្គក្នុងខ្សែសង្វាក់តម្លៃ ដើម្បីបង្កើតផែនទីបង្ហាញពីការអភិវឌ្ឍវិស័យនេះរយៈពេលវែង។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរសហការជាមួយដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសក្នុងតំបន់ ដើម្បីបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងគោលបំណងកែលម្អ និងធានាឱ្យបាននូវផលិតកម្មដំឡូងមីប្រកបដោយនិរន្តរភាព ជាពិសេសដើម្បីបង្កាត់ពូជដំឡូងមីថ្មីៗ ដែលស្របតាមបរិបទអេកូឡូស៊ីកសិកម្មនៅកម្ពុជា និងឆ្លើយតបទៅនឹងទីផ្សារគោលដៅ ព្រមទាំងអភិវឌ្ឍន៍នូវការច្នៃប្រឌិតបង្កើតថ្មី ដើម្បីកាត់បន្ថយចំណាយផលិតកម្មដំឡូងមី និងបង្កើនផលិតភាពកសិកម្ម។
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងពាណិជ្ជកម្ម ដោយសហការជាមួយវិស័យឯកជន គួរតែបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ផលិតផល និងការច្នៃប្រឌិតបង្កើតថ្មី ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ផលិតផលថ្មី ដែលផ្តល់ឲ្យដំឡូងមីនូវអត្ថប្រយោជន៍ប្រកួតប្រជែង និងមានទីផ្សារ រួមទាំងការផ្ទេរចំណេះដឹងទៅឲ្យវិស័យឯកជនយកទៅអនុវត្ត។
- ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវសាងសង់ផ្លូវយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយចម្ងាយពីទីតាំងកែច្នៃទៅកំពង់ផែរបស់ប្រទេស ដែលជាមធ្យោបាយមួយដើម្បីកាត់បន្ថយចំណាយលើការដឹកជញ្ជូន។
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម / ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជាន់ខ្ពស់ ត្រូវតែដឹកនាំធ្វើការវាយតម្លៃផលប៉ះពាល់លើចំណូលសេដ្ឋកិច្ចពីការលាយអេតាណុលដែលបង្កើតចេញពីដំឡូងមី ជាមួយប្រេងសាំង។ ប្រការនេះ អាចនឹងកាត់បន្ថយការនាំចូលប្រេងសាំង ក្នុងទំហំមួយដែលជំនួសដោយអេតាណុលបានមកពីការកែច្នៃក្នុងស្រុក។ ការរៀនសូត្រពីបទពិសោធន៍ជាសកល ដើម្បីទទួលបានការគាំទ្រពីអ្នកប្រើប្រាស់ ប្រេងឧស្ម័ន គួរតែមានតម្លៃថោកជាងប្រេងសាំង ហើយដំណើរការយ៉ាងល្អនៅក្នុងម៉ាស៊ីន ហើយបច្ចុប្បន្ន មានយានយន្តមួយចំនួនកំពុងប្រើប្រាស់ប្រេងឧស្ម័ននេះ។ គោលនយោបាយអេតាណុលដែលមានមូលដ្ឋានផ្អែកលើដំឡូងមីនឹងត្រូវបានបង្កើតឡើង ប្រសិនបើបេកគំហើញមានលក្ខណៈសំខាន់គ្រប់គ្រាន់ផ្នែកសេដ្ឋកិច្ច ដែលអាចសម្រេចបានដោយវិស័យឯកជន ហើយផលិតផលឥន្ធនៈថ្មីនឹងត្រូវបានទទួលយក និងគាំទ្រដោយភ្នាក់ងារទីផ្សារ និងអ្នកប្រើប្រាស់។
- ក្រសួងពាណិជ្ជកម្ម / ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជាន់ខ្ពស់ ត្រូវសិក្សាពីផលចំណេញខាងសេដ្ឋកិច្ចនៃការបង្កើតតំបន់កែច្នៃដំឡូងមីពិសេស។ គោលគំនិតនេះ គឺដើម្បីបង្កើតតំបន់ដែលព័ទ្ធជុំវិញដោយចម្ការ/ខ្សែក្រវ៉ាត់ដំឡូងមី សម្រាប់ការកែច្នៃដំឡូងមីទៅក្នុងលំដាប់នៃផលិតផលដំឡូងមីនៅមួយកន្លែង។ ដំណើរការនេះ គឺសាមញ្ញដោយទទួលបានមើមដំឡូងស្រស់ពីកសិករ ដើម្បីដំណើរការឲ្យទៅជាម្សៅដើម បន្ទាប់មកទៅជាម្សៅកែច្នៃ និងទីបំផុតទៅជាផលិតផលចុងក្រោយ។ ការបង្កើតតំបន់កែច្នៃនេះ គួរតែបង្កើននូវតម្លៃសេដ្ឋកិច្ចយ៉ាងច្រើនសម្រាប់សេដ្ឋកិច្ចជនបទ និងការគ្រប់គ្រងការបំពុលនៅកន្លែងតែមួយ។ ការចំណាយនេះនឹងមានប្រសិទ្ធភាព ព្រោះថាថាមពលដែលបានមកពីកាកសំណល់ដំឡូងមី អាចត្រូវបានប្រើប្រាស់សម្រាប់ឧស្សាហកម្មកែច្នៃទាំងអស់។ ខ្សែសង្វាក់ផលិតកម្ម គឺខ្លី ហើយប្រការនេះអាចជួយសន្សំសំចៃថ្លៃដើម និងចំណាយលើការផ្លាស់ប្តូរសម្ភារដែលត្រូវដំណើរការនៅកន្លែងផ្សេងៗគ្នា។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពិចារណាបង្កើតវិស័យមួយដែលផ្តោតលើសាច់សត្វ និងផលិតផលសាច់កែច្នៃសម្រាប់ការនាំចេញ។ ខ្សែសង្វាក់តម្លៃកសិកម្មទាំងមូលនៅក្នុងប្រទេសកម្ពុជា គួរតែត្រូវបានរួមបញ្ចូលគ្នា ដោយចាប់ផ្តើមពីការផលិតគ្រឿងផ្សំសំខាន់ៗនៃចំណីសត្វ (ដំឡូងមី ពោត ស្រូវ ឬសូម្បីតែសណ្តែកសៀង) បន្ទាប់មក ការផលិតចំណីសត្វ ការអភិវឌ្ឍកសិដ្ឋានចិញ្ចឹមសត្វ ហើយចុងក្រោយ គឺការនាំចេញសាច់សត្វ ឬនាំចេញផលិតផលសាច់ ដែលត្រូវបានដំណើរការក្នុងប្រទេសកម្ពុជា។

## ហានិភ័យ និងការកាត់បន្ថយ

រាជរដ្ឋាភិបាលកម្ពុជា ព្យាករណ៍ពីហានិភ័យដែលអាចប៉ះពាល់ដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃវិធានការគោលនយោបាយ និងសមិទ្ធផលពីគោលដៅរបស់ខ្លួនដូចជា៖

ដំឡូងមី ត្រូវបានគេបិទផ្លាកដោយអបិយជំនឿថា ជាដំណាំនៃការហូរច្រោះដី។ ដូចជាដំណាំម្យ៉ាងទៀតដែរ ដំឡូងមី ស្រូបយកសារធាតុចិញ្ចឹមក្នុងចំនួនដ៏ច្រើនដើម្បីបង្កើតទិន្នផលខ្ពស់ ដូច្នេះ ការហូរច្រោះដីអាចបណ្តាមកពីការដាំដំណាំតែមួយប្រភេទ និងការអនុវត្តកសិកម្មមិនត្រឹមត្រូវក្នុងរយៈពេលជាច្រើនឆ្នាំ។ ដូច្នេះ សុខភាពដី និងជីវជាតិ គួរតែត្រូវបានរក្សាតាមរយៈការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព និងការអនុវត្តកសិកម្មឆ្លាតវៃ។ ប្រព័ន្ធសេវាកម្មផ្សព្វផ្សាយ គួរតែត្រូវបានបង្កើតឡើង និងកែលម្អដើម្បីឈានទៅដល់ការបណ្តុះបណ្តាល និងគាំទ្រដល់កសិករផលិតដំឡូងមី ឲ្យចេះប្រើប្រាស់ដីរបស់ពួកគេប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព។

ប្រទេសកម្ពុជា និងតំបន់ដទៃទៀតនៅអាស៊ី មិនអាចរីករាយជាមួយនឹងបរិស្ថានគ្មានជំងឺ និងគ្មានសត្វល្អិតនោះទៀតទេ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានសត្វល្អិត និងជំងឺមួយចំនួនបានកើតឡើង ដូចជា mosaic disease, witches broom, ពពួកបាក់តេរី សត្វល្អិតចង្រៃ ពីងពាងបៃតង និងប្រភេទជំងឺ និងសត្វល្អិតចង្រៃផ្សេងៗទៀត ដែលត្រូវបានគេរកឃើញនៅតាមតំបន់មួយចំនួនក្នុងប្រទេស។ ការគំរាមកំហែងដែលកំពុងកើតមានឡើង ត្រូវតែគ្រប់គ្រងឲ្យបានម៉ត់ចត់ និងកាត់បន្ថយយ៉ាងសកម្មដើម្បីជៀសវាងការខាតបង់ផ្នែកសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងអនាគត ជាពិសេសការរីករាលដាលទ្រង់ទ្រាយធំដែលមិនអាចគ្រប់គ្រងបាន និងមិនអាចបញ្ឈប់បាននៅដំណាក់កាលក្រោយៗទៀត។ ប្រទេសកម្ពុជា គួរតែសហការជាមួយបណ្តាប្រទេសក្នុងតំបន់ និងវិទ្យាស្ថានស្រាវជ្រាវសកលលោកដើម្បីកាត់បន្ថយហានិភ័យទាំងនេះ។

តម្លៃដំឡូងមី មានការប្រែប្រួលខ្ពស់នៅលើទីផ្សារអន្តរជាតិ និងមិនអាចព្យាករណ៍បានទេនៅប្រទេសកម្ពុជា។ តម្លៃនេះបានទទួលរងឥទ្ធិពលដោយផ្ទាល់ពីតម្រូវការ និងការផ្គត់ផ្គង់ ការជំនួសដោយដំណាំកាបូអ៊ីដ្រាត និងគោលនយោបាយរបស់ប្រទេសនាំចូល។ ផលិតកម្មដំឡូងមី នៅកម្ពុជាមិនអាចគ្រប់គ្រងបានទេ និងមានការប្រែប្រួលលើតម្លៃដោយសារកសិករផ្លាស់ប្តូរទៅដាំដំណាំប្រថុយប្រថានមានតម្លៃខ្ពស់ជាង។ ដូច្នេះដំឡូងមី គួរតែត្រូវបានលើកកម្ពស់ជាដំណាំយុទ្ធសាស្ត្រដែលផលចំណេញនៅឯកសិដ្ឋានគួរតែត្រូវបានកែលម្អ និងទីផ្សារគួរតែត្រូវបានធានាតាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យា។

ការលើកកម្ពស់ការនាំចេញផលិតផលជំឡូងមីដោយផ្ទាល់ពីប្រទេសកម្ពុជា ប្រឈមនឹងការប្រកួតប្រជែងយ៉ាងខ្លាំងពីប្រទេសជិតខាងដែលបានគ្របដណ្ដប់ផលិតកម្មជំឡូងមីក្នុងស្រុក និងទីផ្សារពិភពលោកអស់រយៈពេលជាយូរមកហើយ។ ដោយពាណិជ្ជកម្មមានការប្រកួតប្រជែងខ្ពស់ ប្រទេសខ្លះអាចកេងប្រវ័ញ្ចលើតម្លៃ ឬកំណត់តម្លៃដែលធ្វើឱ្យការនាំចេញពីផ្លូវពាណិជ្ជកម្មរបស់ប្រទេសមិនអាចទទួលយកបាន។ ការលើកកម្ពស់ការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម ទាមទារឱ្យមានភាពជាដៃគូប្រកបដោយប្រសិទ្ធភាពរវាងអ្នកផលិតសាធារណៈនិងឯកជន ដែលជាធនធានអាចរកបាន ដែលគួរត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងមានការគាំទ្រដោយផ្ទាល់ពីរដ្ឋាភិបាល។

ម្យ៉ាងវិញទៀត ផលិតផលពីប្រទេសកម្ពុជាគួរតែមានតម្លៃ និងគុណភាពដូចគ្នាខណៈលក្ខខណ្ឌពាណិជ្ជកម្មគួរមានការទាក់ទាញ។ លក្ខខណ្ឌទាំងនេះ ប្រឈមនឹងវិស័យឯកជនកម្ពុជាដោយសារក្រុមហ៊ុនភាគច្រើន គឺជាអាជីវកម្មមានលក្ខណៈមិនរៀបរយគ្រប់គ្រងដោយគ្រួសារខ្នាតតូច និងមិនមានវិជ្ជាជីវៈដែលមិនមានប្រសិទ្ធភាព ខ្វះខាតដើមទុន គ្មានការធានាលើគុណភាពផលិតផល និងប្រើប្រាស់បច្ចេកវិទ្យា និងឧបករណ៍ហួសសម័យ។ ក្រៅពីបង្កើនការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម ការជំរុញសហគ្រាសខ្នាតតូច និងមធ្យម ឱ្យឈានដល់ស្តង់ដារអាជីវកម្មអន្តរជាតិ និងការទាក់ទាញការវិនិយោគទ្រង់ទ្រាយធំ ជាមួយនឹងការយល់ដឹងអំពីអាជីវកម្ម និងការត្រៀមខ្លួន គឺជាអាទិភាពអភិវឌ្ឍន៍បន្ទាន់។

## ការរៀបចំអភិបាលកិច្ចវិស័យជំឡូងមី

ដោយសារខ្សែសង្វាក់តម្លៃជំឡូងមីកម្ពុជា មិនមានរបៀបរៀបរយ ហើយការអភិវឌ្ឍរបស់វិស័យនេះ មានអន្តរទំនាក់ទំនងជាមួយវិស័យជាច្រើនទៀត រចនាសម្ព័ន្ធអភិបាលកិច្ចវិស័យជំឡូងមី គួរតែត្រូវបានបង្កើតឡើងជាមួយនឹងសមត្ថភាពដើម្បីធ្វើប្រតិបត្តិការសម្របសម្រួល និងគ្រប់គ្រងអន្តរកម្មដែលមានលក្ខណៈចម្រុះនិងស្មុគស្មាញរវាងអ្នកពាក់ព័ន្ធនានា ក្នុងគោលបំណងអនុវត្តគោលនយោបាយជំឡូងមីឲ្យមានប្រសិទ្ធភាព។ អង្គភាព/ស្ថាប័ន/ទីភ្នាក់ងារដែលមានស្រាប់ ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវចំពោះភារកិច្ចដែលពាក់ព័ន្ធនៅក្នុងអាណត្តិរបស់ពួកគេ ហើយធនធានមនុស្សគួរតែត្រូវបានតែងតាំងតាមការសមស្រប និងជាមូលដ្ឋានចាំបាច់ដើម្បីបំពេញការងារ។

ដើម្បីអនុវត្តគោលនយោបាយនេះប្រកបដោយជោគជ័យ រាជរដ្ឋាភិបាលកម្ពុជា កំណត់ភារកិច្ច ដូចខាងក្រោម៖

- គណៈកម្មាធិការស្តីពីគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវលើការពិនិត្យតាមដាន វាយតម្លៃ និងសម្របសម្រួលនូវកម្រិតគោលនយោបាយ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នា និងតម្រែតម្រង់គោលនយោបាយនេះឲ្យស្របគ្នាជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធដទៃទៀត។
- ក្រុមការងារជំឡូងមី ដែលបានបង្កើតឡើងដោយក្រសួងពាណិជ្ជកម្ម តាមរយៈប្រកាសចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៧ ត្រូវប្រែក្លាយទៅជាក្រុមការងារផ្លូវការរបស់វេទិការវាងរដ្ឋាភិបាលនិងវិស័យឯកជន

(G-PSF) ហៅថាក្រុមការងារទី ១១។ ក្រុមការងារនេះ មានគណៈកម្មាធិការស្តីពីគោលនយោបាយ និងការគ្រប់គ្រងដំឡូងមី និងលេខាធិការដ្ឋាន។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ត្រូវទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងការផ្តល់ហិរញ្ញប្បទានស្របតាមស្មារតីនៃឯកសារគោលនយោបាយនេះ។
- ក្រសួង/ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តមុខងាររបស់ខ្លួន ស្របតាមការទទួលខុសត្រូវដែលត្រូវបានកំណត់ដូចមានចែងនៅក្នុងវិធានការគោលនយោបាយ និងការរៀបចំស្ថាប័នខាងលើ។ ពួកគេត្រូវរាយការណ៍ពីវឌ្ឍនភាព និងរៀបចំសំណើរកែប្រែ ឬវិធានការបន្ថែមទៅឱ្យនាយករដ្ឋមន្ត្រី ដើម្បីធ្វើការសម្រេចចិត្ត និងការណែនាំតាមតម្រូវការចាំបាច់។

## សេចក្តីសន្និដ្ឋាន

គោលនយោបាយនេះ មានគោលបំណងបំលែងដំឡូងមី ឲ្យទៅជាដំណាំដែលទទួលបានផលចំណេញសម្រាប់កសិករខ្នាតតូច និងជាប្រភពនៃការអភិវឌ្ឍឧស្សាហកម្មនៅប្រទេសកម្ពុជា។ ដើម្បីចាប់ផ្តើមដំណើរការផ្លាស់ប្តូរនេះ ការធ្វើពាណិជ្ជកម្មផលិតកម្មដំឡូង និងការអភិវឌ្ឍកសិ-អាជីវកម្មគួរតែត្រូវបានធ្វើឡើងក្នុងពេលតែមួយ ដើម្បីលើកកម្ពស់ការប្រកួតប្រជែងលើផលិតផលដំឡូងមីដែលបានដាំ និងកែច្នៃក្នុងប្រទេសកម្ពុជា ទល់នឹងដំណាំជំនួស / ផលិតផលដំណាំពីតំបន់ផ្សេងៗទៀតនៃពិភពលោក។ ភាពប្រកួតប្រជែងនេះ បង្កើតឡើងនៅក្នុងផលចំណេញនៃអ្នកដើរតួសំខាន់ៗនៃខ្សែសង្វាក់ផលិតកម្មក្នុងបរិបទនៃការប្រែប្រួលតម្លៃ។

រាជរដ្ឋាភិបាលកម្ពុជា មើលឃើញពីលទ្ធភាពនៃការអភិវឌ្ឍវិស័យដំឡូងមី ព្រោះវាជាដំណាំដែលកំពុងដាំដុះដោយកសិករខ្នាតតូចជាច្រើនរួចមកហើយ។ អត្ថប្រយោជន៍នៃការប្រកួតប្រជែង នៅតែមាននៅឯកសិដ្ឋាន និងអាចបន្តកើតឡើងទៅពេលមុខទៀត។ ដូច្នេះ ការលើកកម្ពស់អ្នកកែច្នៃដែលមានស្រាប់ និងការទាក់ទាញការវិនិយោគដើម្បីសាងសង់រោងចក្រទំនើបទាន់សម័យ ការដោះស្រាយបញ្ហាផលិតកម្មដំឡូងមី និងកែលម្អបរិយាកាសអាជីវកម្មដែលមានលក្ខណៈអំណោយផលអាចជួយលើកកម្ពស់ការប្រកួតប្រជែងវិស័យនេះទាំងមូល។

ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃវិធានការគោលនយោបាយខាងលើនេះ នឹងនាំទៅដល់ការសម្រេចគោលដៅ។ ជាលទ្ធផល ប្រការនេះនឹងនាំមកនូវកំណើនសេដ្ឋកិច្ចយ៉ាងច្រើនដល់ប្រទេសកម្ពុជា ស្របតាមគន្លងអន្តរកាលរបស់ប្រទេសពីការអភិវឌ្ឍតិចតួច ឆ្ពោះទៅរកការអភិវឌ្ឍប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។

-------------------------